**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia

National Region King

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

Ministry of Industry, Mines and Energy

លេខៈ ៦១៨ ឧរថ.មឧក.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅ
# របស់មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការដំឡើងមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ទៅជាថ្នាក់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលិខិតលេខ ៧៨៨ ឧរថ.មស.លស ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង

# សម្រេច

**ប្រការ ១.**–

មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា អក្សរកាត់ "**ម.ម.ឧ.ក**" ស្ថិតនៅក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលមានតួនាទី និងភារកិច្ចដូចតទៅ:

- វិភាគ ធ្វើតេស្ត ផ្នែករូបសាស្ត្រ គីមីសាស្ត្រ មីក្រូជីវសាស្ត្រ មេកានិច ដើម្បីកំណត់គុណភាព និងលក្ខណៈវិនិច្ឆ័យរបស់ផលិតផល
- សហការស្រាវជ្រាវ ផ្សព្វផ្សាយ និងផ្តល់យោបល់ ពីគុណភាព សុវត្ថិភាពផលិតផល បច្ចេកវិទ្យាក្នុងការកែច្នៃ ការរក្សាទុក និងបង្កើតផលិតផលថ្មី
- សហប្រតិបត្តិការជាមួយមន្ទីរពិសោធន៍នៃស្ថាប័នជាតិ និងអន្តរជាតិ
- បង្កើនសមត្ថភាពមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ឱ្យទទួលបានការវាយតម្លៃទទួលស្គាល់ពីស្ថាប័នជាតិ និងអន្តរជាតិ ។

**ប្រការ ២.**–

មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ត្រូវបានដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៣.**–

មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ:

១- ការិយាល័យរដ្ឋបាល ផែនការ និងសេវាទូទៅ

២- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

៣- ការិយាល័យមីក្រូជីវសាស្ត្រចំណីអាហារ

៤- ការិយាល័យគីមីសាស្ត្រទឹក

៥- ការិយាល័យគីមីសាស្ត្រចំណីអាហារ

៦- ការិយាល័យគីមីសាស្ត្រមិនមែនចំណីអាហារ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៤.**–

អំពីតួនាទី និងភារកិច្ចរបស់ការិយាល័យនីមួយៗ:

## ១- ការិយាល័យរដ្ឋបាល ផែនការ និងសេវាទូទៅ

**តួនាទី:**

ការិយាល័យរដ្ឋបាល ផែនការ និងសេវាទូទៅ ជាអង្គភាពសេនាធិការជំនួយការថ្នាក់ដឹកនាំមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា លើការងាររដ្ឋបាល ផែនការ បុគ្គលិក សរុបការងារ អង្កេត វាយតម្លៃលើសកម្មភាពតាមការិយាល័យនីមួយៗ គ្រប់គ្រងបណ្ណាល័យ បណ្តុះបណ្តាលមន្ត្រីរាជការក្នុងមជ្ឈមណ្ឌល និងការងារសេវាទូទៅរួមមានការទទួលសំណាកគំរូ ការចេញវិញ្ញាបនប័ត្រវិភាគគុណភាពផលិតផល និងការបណ្តុះបណ្តាលប្រឹក្សាជាមួយអតិថិជន។

**ភារកិច្ច:**

- គ្រប់គ្រងលិខិតចេញ ចូលគ្រប់ប្រភេទ និងបែងចែកលិខិតទាំងនោះទៅតាមការិយាល័យនីមួយៗ
- គ្រប់គ្រងការងារមន្ត្រីរាជការក្នុងមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា
- អង្កេត និងវាយតម្លៃលើលទ្ធផលនៃការអនុវត្តន៍ការងាររបស់ការិយាល័យនីមួយៗ
- ធ្វើរបាយការណ៍សរុបការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- រៀបចំផែនការសកម្មភាពការងាររបស់មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា
- តាមដាន និងសម្របសម្រួលការងារផែនការស្រាវជ្រាវប្រចាំឆ្នាំ
- ទំនាក់ទំនងសេវាទូទៅរបស់មជ្ឈមណ្ឌល និងទំនាក់ទំនងព័ត៌មានជាមួយអតិថិជន
- រៀបចំកម្មវិធី សម្របសម្រួលជាមួយអតិថិជន និងការិយាល័យនីមួយៗរបស់មជ្ឈមណ្ឌលក្នុងការចុះយកសំណាកគំរូដើម្បីធ្វើការវិភាគ
- រៀបចំចេញ និងផ្តល់វិញ្ញាបនប័ត្រវិភាគគុណភាពជូនអតិថិជន
- សម្របសម្រួលជាមួយការិយាល័យនីមួយៗដើម្បីផ្តល់សេវាប្រឹក្សាដល់អតិថិជនដែលពាក់ព័ន្ធទៅនឹងលទ្ធផលនៃការធ្វើវិភាគ ក្នុងទិសដៅលើកកម្ពស់គុណភាព សុវត្ថិភាពផលិតផល
- សម្របសម្រួលជាមួយការិយាល័យនីមួយៗដើម្បីផ្តល់សេវាដល់អតិថិជនក្នុងការបណ្តុះបណ្តាល ការធ្វើវិភាគ ការជួយរៀបចំបង្កើតមន្ទីរពិសោធន៍ ការសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍបច្ចេកវិទ្យា និងផលិតផល
- រៀបចំកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗ
- ប្រមូលទិន្នន័យព័ត៌មាន និងលទ្ធផលនៃការស្រាវជ្រាវតាមការិយាល័យជំនាញ ដើម្បីរៀបចំចងក្រងបោះពុម្ព សំរាប់បណ្តុះបណ្តាល និងផ្សព្វផ្សាយ
- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាស្រាវជ្រាវ និងបណ្ណាល័យ
- សហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ និងលើកផែនការបណ្តុះបណ្តាលដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស
- សម្របសម្រួលក្នុងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវ និងមន្ទីរពិសោធន៍នានា និងគម្រោងជំនួយដែលផ្តល់ដោយស្ថាប័នជាតិ និងអន្តរជាតិ។

## ២- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

**តួនាទី:**

ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ ជាអង្គភាពសេនាធិការជំនួយការថ្នាក់ដឹកនាំមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា លើការងារគណនេយ្យ និងហិរញ្ញវត្ថុ។

**ភារកិច្ច:**

- រៀបចំ និងគ្រប់គ្រងការងារផែនការទូទៅ ការលើកគម្រោងថវិកាចំណាយ ឧបត្ថម្ភធនប្រចាំឆ្នាំ និងតាមដានរំលឹកពីការប្រតិបត្តិរបស់ ម.ម.ឧ.ក
- ទទួលខុសត្រូវគណនេយ្យកិច្ច គ្រប់គ្រងបញ្ជីកាគណនេយ្យ និងថវិកាសម្រាប់ដំណើរការការងាររបស់មជ្ឈមណ្ឌល
- គ្រប់គ្រងរៀបចំចំណូលពីផលការងារ និងកម្រៃនៃការផ្តល់សេវាផ្សេងៗ ពិនិត្យកត់ត្រា ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈឧបករណ៍ពិសោធន៍ និងធ្វើបញ្ជីសារពើភ័ណ្ឌរបស់មជ្ឈមណ្ឌល

## ៣- ការិយាល័យមីក្រូជីវសាស្ត្រចំណីអាហារ

**តួនាទី:**

ការិយាល័យមីក្រូជីវសាស្ត្រចំណីអាហារ ជាអង្គភាពសេនាធិការជំនួយការថ្នាក់ដឹកនាំមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា លើការងារសិក្សាស្រាវជ្រាវ និងវិភាគផ្នែកមីក្រូជីវសាស្ត្រចំណីអាហារ និងទឹក។

**ភារកិច្ច:**

- វិភាគផ្នែកមីក្រូជីវសាស្ត្រលើចំណីអាហារ
- វិភាគផ្នែកមីក្រូជីវសាស្ត្រលើទឹកពិសារ ទឹកកក និងទឹកគ្រប់ប្រភេទ
- វិភាគផ្នែកមីក្រូជីវសាស្ត្រលើសំណល់រាវ
- ផ្តល់ប្រឹក្សាដល់អតិថិជនដើម្បីកែលម្អ និងលើកកម្ពស់គុណភាព សុវត្ថិភាពផលិតផល ដែលពាក់ព័ន្ធនឹងផ្នែកមីក្រូជីវសាស្ត្រលើចំណីអាហារ និងទឹក
- ផ្តល់ការបណ្តុះបណ្តាលដល់អតិថិជន ស្តីពីការវិភាគផ្នែកមីក្រូជីវសាស្ត្រចំណីអាហារ និងទឹក និងប្រព័ន្ធគ្រប់គ្រងគុណភាព
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍលើផលិតផល និងវិធីសាស្ត្រនៃការវិភាគផ្នែកមីក្រូជីវសាស្ត្រចំណីអាហារ និងទឹក។

## ៤- ការិយាល័យគីមីសាស្ត្រទឹក

**តួនាទី:**

ការិយាល័យគីមីសាស្ត្រទឹក ជាអង្គភាពសេនាធិការជំនួយការថ្នាក់ដឹកនាំមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា លើការងារសិក្សាស្រាវជ្រាវ និងវិភាគផ្នែកគីមីសាស្ត្រលើទឹកគ្រប់ប្រភេទ។

**ភារកិច្ចៈ**

- វិភាគផ្នែកគីមីសាស្ត្រលើទឹកពិសា ទឹកកក និងទឹកគ្រប់ប្រភេទ
- វិភាគផ្នែកគីមីសាស្ត្រលើសំណល់វារី
- ផ្ដល់ប្រឹក្សាដល់អតិថិជនដើម្បីកែលម្អ និងលើកកម្ពស់គុណភាព សុវត្ថិភាពលើការប្រើប្រាស់ទឹកគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងផ្នែកគីមីសាស្ត្រ
- ផ្ដល់ការបណ្ដុះបណ្ដាលដល់អតិថិជន ស្ដីពីការវិភាគផ្នែកគីមីសាស្ត្រលើទឹកគ្រប់ប្រភេទ និងប្រព័ន្ធគ្រប់គ្រងគុណភាព
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍលើផលិតផលទឹកពិសា ទឹកកក ទឹកប្រើប្រាស់ ទឹកប្រភព និងវិធីសាស្ត្រនៃការវិភាគផ្នែកគីមីសាស្ត្រទឹក។

## ៥- ការិយាល័យគីមីសាស្ត្រចំណីអាហារ

**តួនាទីៈ**

ការិយាល័យគីមីសាស្ត្រចំណីអាហារ ជាអង្គភាពសេនាធិការជំនួយការថ្នាក់ដឹកនាំមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា លើការងារសិក្សាស្រាវជ្រាវ និងវិភាគផ្នែកគីមីសាស្ត្រលើចំណីអាហារគ្រប់ប្រភេទ។

**ភារកិច្ចៈ**

- វិភាគផ្នែកគីមីសាស្ត្រលើផលិតផលភេសជ្ជៈគ្រប់ប្រភេទ
- វិភាគផ្នែកគីមីសាស្ត្រលើផលិតផលចំណីអាហារគ្រប់ប្រភេទ
- ផ្ដល់ប្រឹក្សាដល់អតិថិជនដើម្បីកែលម្អ និងលើកកម្ពស់គុណភាព សុវត្ថិភាពផលិតផលចំណីអាហារដែលពាក់ព័ន្ធនឹងផ្នែកគីមីសាស្ត្រ
- ផ្ដល់ការបណ្ដុះបណ្ដាលដល់អតិថិជន ស្ដីពីការវិភាគផ្នែកគីមីសាស្ត្រចំណីអាហារ និងប្រព័ន្ធគ្រប់គ្រងគុណភាព
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍលើផលិតផលវិធីសាស្ត្រនៃការវិភាគផ្នែកគីមីសាស្ត្រចំណីអាហារ។

## ៦- ការិយាល័យគីមីសាស្ត្រមិនមែនចំណីអាហារ

**តួនាទីៈ**

ការិយាល័យគីមីសាស្ត្រមិនមែនចំណីអាហារ ជាអង្គភាពសេនាធិការជំនួយការថ្នាក់ដឹកនាំមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា លើការងារសិក្សាស្រាវជ្រាវ និងវិភាគផ្នែកគីមីសាស្ត្រលើវត្ថុធាតុដើម សារធាតុគីមី និងផលិតផលមិនមែនចំណីអាហារ។

**ភារកិច្ចៈ**

- វិភាគផ្នែកគីមីសាស្ត្រលើវត្ថុធាតុដើម
- វិភាគផ្នែកគីមីសាស្ត្រលើសារធាតុគីមី និងផលិតផលមិនមែនចំណីអាហារ
- ផ្ដល់ប្រឹក្សាដល់អតិថិជនដើម្បីកែលម្អគុណភាព សុវត្ថិភាពផលិតផលមិនមែនចំណីអាហារដែលពាក់ព័ន្ធនឹងផ្នែកគីមីសាស្ត្រ

- ផ្តល់ការបណ្តុះបណ្តាលដល់អតិថិជន ស្តីពីការវិភាគផ្នែកគីមីសាស្រ្តមិនមែនចំណីអាហារ និងប្រព័ន្ធគ្រប់គ្រងគុណភាព
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍលើផលិតផល និងវិធីសាស្រ្តនៃការវិភាគផ្នែកគីមីសាស្រ្តមិនមែនចំណីអាហារ ។

**ប្រការ ៥.–**

ប្រកាស និងសេចក្តីសម្រេចទាំងឡាយណាដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.–**

អគ្គនាយកនៃនាយកដ្ឋានឧស្សាហកម្ម អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធានមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ ៧.–**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ស៊ុយ សែម**

**កន្លែងទទួលៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- គ្រប់អគ្គនាយកដ្ឋាន វិទ្យាស្ថាន និងអគ្គាធិការដ្ឋាន
- គ្រប់នាយកដ្ឋានសេនាធិការក្រសួង
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-រាជធានី
  " ដើម្បីជ្រាបជាព័ត៌មាន "
- ដូចប្រការ ៦ " ដើម្បីអនុវត្ត "
- ឯកសារ–កាលប្បវត្តិ

**តារាងឧបសម្ព័ន្ធទី ១ នៃប្រកាសលេខ** ៖ ៦១៨ ឧរថ.មឧក.ប្រក

ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩

# រចនាសម្ព័ន្ធមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា




| | | |
|---|---|---|
| **បានឃើញ** | **បានឃើញ** | ភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩ |
| ភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ | ភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៩ | **ប្រធានមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា** |
| **រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** | **អគ្គនាយកឧស្សាហកម្ម** | |
| **ស៊ុយ សែម** | **ម៉េង សក្តិធារ៉ា** | **អ៊ុន សំបូរ** |